F1245
S-1330

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

លេខ......០៣៤......អ.ស.ហ..ប្រក

# ប្រកាស
## ស្តីពី
## ការបង្ហាញព័ត៌មានចីរភាព

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០០៧/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម
- បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំ នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ .-**

ប្រកាសនេះកំណត់ពីការបង្ហាញព័ត៌មានចីរភាពពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច ដោយបុគ្គលចុះបញ្ជីលក់មូលបត្រ ដើម្បីជានាឱ្យបាននូវតម្លាភាព ភាពដែលអាចប្រៀបធៀបបាន និងគណនេយ្យភាពចំពោះហានិភ័យនៃផលប៉ះពាល់ជាសារវន្ត ឬដែលកើតចេញពីបរិស្ថានឬសហគមន៍របស់បុគ្គលចុះបញ្ជីលក់មូលបត្រ តាមរយៈការអនុវត្តអភិបាលកិច្ចល្អ និងស្តង់ដាសង្គម។

**ប្រការ ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រនៅព្រះរាជាណាចក្រកម្ពុជា លើកលែងតែបុគ្គលចុះបញ្ជីលក់មូលបត្រនៅក្នុងទីផ្សារកំណើនដែលអាចអនុវត្តតាមគោលការណ៍ស្ម័គ្រចិត្ត។

**ប្រការ ៣ .-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន÷

**១- ផលប៉ះពាល់ជាសារវន្ត** សំដៅដល់ព័ត៌មានអំពីផលប៉ះពាល់ដែលត្រូវបង្ហាញ ឬមិនត្រូវបង្ហាញជាសាធារណៈ ហើយព័ត៌មាននេះត្រូវបានរំពឹងទុកយ៉ាងសមស្របថាមានឥទ្ធិពលដល់ការសម្រេចចិត្តរបស់វិនិយោគិន ឬប៉ះពាល់ដល់ការវាយតម្លៃលើតម្លៃរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលកើតចេញពីគំរូអាជីវកម្ម យុទ្ធសាស្ត្រ លំហូរសាច់ប្រាក់នាពេលអនាគត លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងចំណាយមូលធន ជាអាទិ៍។

**២- ស្តង់ដាអភិបាលកិច្ច** សំដៅដល់យន្តការ ការអនុវត្ត និងការបង្ហាញព័ត៌មានដូចមានកំណត់ក្នុង ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន និងគោលការណ៍ទាំងឡាយពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្ម។

**៣- ហានិភ័យបរិស្ថាន** សំដៅដល់ហានិភ័យដែលកើតចេញពីសកម្មភាពអាជីវកម្ម និងប្រតិបត្តិការរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលអាចប៉ះពាល់ជាសារវន្តដល់បរិស្ថាន ឬកើតចេញពីបរិស្ថាន ឬប៉ះពាល់ដល់បរិស្ថានរបស់អតិថិជនដែលបុគ្គលចុះបញ្ជីលក់មូលបត្របានលក់ផលិតផល ឬសេវាកម្ម ដោយផលប៉ះពាល់នេះមានពាក់ព័ន្ធនឹងសកម្មភាពណាមួយជាក់លាក់ ឬសកម្មភាពច្រើនប្រមូលផ្តុំរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។ ផលប៉ះពាល់នេះរួមមាន ផលប៉ះពាល់លើអាកាសធាតុ គុណភាពដី ទឹក ខ្យល់ ព្រៃធម្មជាតិ ដែនជម្រកសត្វព្រៃ ជីវៈចម្រុះ ទ្រព្យ និងធនធានធម្មជាតិសំខាន់ៗផ្សេងទៀត។

**៤- ហានិភ័យសង្គម** សំដៅដល់ហានិភ័យដែលកើតចេញពីសកម្មភាពអាជីវកម្ម និងប្រតិបត្តិការរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលអាចប៉ះពាល់ជាសារវន្តដល់សហគមន៍ ឬកើតចេញពីសហគមន៍ របស់បុគ្គលចុះបញ្ជីលក់មូលបត្រ ឬដែលបុគ្គលចុះបញ្ជីលក់មូលបត្របានលក់ផលិតផល ឬសេវាកម្ម ដោយផលប៉ះពាល់នេះមានពាក់ព័ន្ធនឹងសកម្មភាពជាក់លាក់ណាមួយ ឬសកម្មភាពច្រើនប្រមូលផ្តុំរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។ ផលប៉ះពាល់នេះរួមមាន ផលប៉ះពាល់លើសុខុមាលភាព និងសុវត្ថិភាពការងាររបស់និយោជិត សមភាពយេនឌ័រ ការទទួលបានសេវាសុខភាព និងតម្រូវការជាមូលដ្ឋានរបស់សហគមន៍ ដូចជា ទឹក អគ្គិសនី និងសន្តិសុខស្បៀង។

## ជំពូកទី ២
## ការបង្ហាញព័ត៌មានស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ច

**ប្រការ ៤ ._**

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញព័ត៌មានដូចមានក្នុងតារាង “ក” ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។ តារាង “ក” កំណត់អំពីព័ត៌មាន ដែលពិពណ៌នាអំពីហានិភ័យបរិស្ថាន និងសង្គមរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

សម្រាប់ព័ត៌មាននីមួយៗនៅក្នុងតារាង “ក” ÷

១- ករណីបុគ្គលចុះបញ្ជីលក់មូលបត្រមានព័ត៌មានដូចបានកំណត់ក្នុងតារាង “ក” ឬប្រហាក់ប្រហែលដែលមានស្រាប់ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្សព្វផ្សាយជាសាធារណៈ។ ករណីព័ត៌មានបានបង្ហាញជាសាធារណៈស្រាប់ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបញ្ជាក់ឱ្យបានច្បាស់នៅក្នុងតារាងអំពីមធ្យោបាយដែលអាចស្វែងរកព័ត៌មាននេះបាន។

២- ករណីបុគ្គលចុះបញ្ជីលក់មូលបត្រមិនមានព័ត៌មានដូចបានកំណត់នៅក្នុងតារាង បុគ្គលចុះបញ្ជីលក់មូលបត្រគួរបញ្ជាក់ និងពន្យល់ពីផលប៉ះពាល់ជាសក្តានុពលនៃហានិភ័យត្រូវបានចាត់ទុក ឬមិនចាត់ទុកជាសារវន្ត សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រ។ ករណីមិនចាត់ទុកជាសារវន្ត បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវពន្យល់មូលហេតុ។ ករណីចាត់ទុកជាសារវន្ត បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវពន្យល់ពីវិធានការដែលក្រុមហ៊ុនគ្រោងនឹងអនុវត្ត។

ក្រុមប្រឹក្សាភិបាលនៃបុគ្គលចុះបញ្ជីលក់មូលបត្រត្រូវធានានូវភាពពេញលេញ ភាពត្រឹមត្រូវ និងភាពមិននាំឱ្យមានការយល់ខុសនៃព័ត៌មាននៅក្នុងតារាង។ បុគ្គលចុះបញ្ជីលក់មូលបត្រអាចតែងតាំងអ្នកត្រួតពិនិត្យឯករាជ្យដើម្បីត្រួតពិនិត្យទៅលើភាពពេញលេញ និងត្រឹមត្រូវនៃព័ត៌មាននៅក្នុងតារាង។ ករណីបុគ្គលចុះបញ្ជីលក់មូលបត្របានតែងតាំងអ្នកត្រួតពិនិត្យឯករាជ្យនេះ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការតែងតាំង អត្តសញ្ញាណ វិសាលភាពនៃការពិនិត្យឡើងវិញ និងការសន្និដ្ឋានលម្អិតរបស់អ្នកត្រួតពិនិត្យឯករាជ្យ។

**ប្រការ ៥ .-**

បុគ្គលចុះបញ្ជីលក់មូលបត្រអាចបង្ហាញព័ត៌មានដូចមានកំណត់ក្នុងតារាង “ខ” តាមការចាំបាច់។ តារាង “ខ” កំណត់អំពីព័ត៌មានបន្ថែមពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថាន និងសង្គមរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

បុគ្គលចុះបញ្ជីលក់មូលបត្រអាចបង្ហាញជាសាធារណៈនូវព័ត៌មានដូចមានកំណត់ក្នុងតារាង “ខ” ទាំងស្រុង ឬអាចជ្រើសរើសព័ត៌មានមួយចំនួនពីតារាង “ខ” មកបង្ហាញជាសាធារណៈ។

**ប្រការ ៦ .-**

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញព័ត៌មានដូចមានកំណត់ក្នុងតារាង “ក” ជាឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ។ ករណីបុគ្គលចុះបញ្ជីលក់មូលបត្របង្ហាញព័ត៌មានដូចមានក្នុងតារាង “ខ” បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញព័ត៌មាននោះជាឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំផងដែរ។ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញព័ត៌មានក្នុងទម្រង់ និងលំដាប់ដូចគ្នាដូចមានកំណត់ក្នុងតារាងដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ករណីបុគ្គលចុះបញ្ជីលក់មូលបត្ររៀបចំ និងបង្ហាញរបាយការណ៍ចីរភាពដោយអនុលោមតាមក្របខណ្ឌ និងស្តង់ដាអន្តរជាតិដែលទទួលស្គាល់ របាយការណ៍នេះត្រូវចាត់ទុកថាអនុលោមតាមទម្រង់របាយការណ៍ដែលកំណត់ដោយប្រកាសនេះ។ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវភ្ជាប់របាយការណ៍ចីរភាពនេះជាឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ ឬបញ្ជាក់អំពីតំណភ្ជាប់នៃរបាយការណ៍ចីរភាពនេះ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

## ជំពូកទី ៣
## ទោសប្បញ្ញត្តិ

**ប្រការ ៧ .-**

បុគ្គលចុះបញ្ជីលក់មូលបត្រ និង/ ឬបុគ្គលពាក់ព័ន្ធ ដែលល្មើសនឹងប្រការ ៤ ប្រការ ៦ ឬប្រការ ៩ នៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលពីអគ្គនាយកនៃ **ន.ម.ក.** ដូចខាងក្រោម÷

១- ការព្រមាន។

២- ការដឹកនាំកែតម្រង់។

៣- ការប្រកាសជាសាធារណៈ នូវទណ្ឌកម្មរបស់បុគ្គលដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៤- ការដាក់កំហិតលើការបោះផ្សាយលក់មូលបត្រ។

៥- ការផ្តល់អនុសាសន៍លើការបណ្តេញចេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។

៦- ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រ ឬការចែកចាយបន្ទាប់។

**ប្រការ ៨ .-**

ការអនុវត្តទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះមិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**ប្រការ ៩ .-**

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវអនុវត្តប្រកាសនេះបន្ទាប់ពីរយៈពេល ២៤ (ម្ភៃបួន) ខែ គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើប្រកាសនេះ។

បុគ្គលចុះបញ្ជីលក់មូលបត្រអាចអនុវត្តប្រកាសនេះដោយស្ម័គ្រចិត្ត បន្ទាប់ពីកាលបរិច្ឆេទចុះហត្ថលេខា។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ១០ .-**

**ន.ម.ភ.** អាចចេញគោលការណ៍ណែនាំសម្រាប់ការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ និងដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះរបស់បុគ្គលពាក់ព័ន្ធ និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងសាធារណជន។

**ប្រការ ១១ .-**

អគ្គលេខាធិការ អគ្គនាយកនៃនិយ័តករ និងប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៣ កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាព និងសមាសភាពក្រុមប្រឹក្សានៃ **អ.ស.ហ.**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**តារាង "ក"**

| ព័ត៌មានប្រតិបត្តិការ | |
|---|---|
| ១ | គំរូអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ<br>....................................................................................................<br>....................................................................................................<br>.................................................................................................... |
| **អភិបាលកិច្ចប្រកបដោយចីរភាព** | |
| ២ | វិធានការ ឬមធ្យោបាយដែលបុគ្គលចុះបញ្ជីលក់មូលបត្របាន ឬគ្រោង កំណត់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជាក់លាក់នៅក្នុងយុទ្ធសាស្ត្រអាជីវកម្ម ឬអភិបាលកិច្ច ការគ្រប់គ្រង ឬដំណើរការប្រតិបត្តិការ របស់បុគ្គលចុះបញ្ជីលក់មូលបត្រ<br>....................................................................................................<br>....................................................................................................<br>.................................................................................................... |
| ៣ | ហានិភ័យសំខាន់ៗទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម សម្រាប់រយៈពេលខ្លី មធ្យម ឬវែង ដែលបុគ្គលចុះបញ្ជីលក់មូលបត្រកំណត់អត្តសញ្ញាណហានិភ័យទាំងនេះដែលកើតទៅលើប្រតិបត្តិការរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ<br>....................................................................................................<br>....................................................................................................<br>.................................................................................................... |
| ៤ | ប្រតិបត្តិការគ្រប់គ្រងហានិភ័យ÷ ដំណើរការដែលត្រូវបានប្រើប្រាស់ដោយបុគ្គលចុះបញ្ជីលក់មូល-បត្រក្នុងការកំណត់អត្តសញ្ញាណ និងគ្រប់គ្រងហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម<br>....................................................................................................<br>....................................................................................................<br>.................................................................................................... |
| ៥ | យុទ្ធសាស្ត្រ ឬផែនការដែលបុគ្គលចុះបញ្ជីលក់មូលបត្រអនុវត្តដើម្បីគ្រប់គ្រងហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម<br>....................................................................................................<br>....................................................................................................<br>.................................................................................................... |
| ៦ | អភិបាលកិច្ចនៃហានិភ័យ÷ ដំណើរការអភិបាលកិច្ច និងការរាយការណ៍ដែលត្រូវបានប្រើប្រាស់ដោយក្រុមប្រឹក្សាភិបាលនៃបុគ្គលចុះបញ្ជីលក់មូលបត្រ ក្នុងការត្រួតពិនិត្យលើហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម<br>....................................................................................................<br>....................................................................................................<br>.................................................................................................... |

| | |
|---|---|
| ៧ | ម៉ាទ្រីស សូចនាករ និងការវាស់វែងសំខាន់ៗ ដែលបុគ្គលចុះបញ្ជីលក់មូលបត្រប្រើប្រាស់ក្នុងការតាមដាន និងវាយតម្លៃហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម<br>..........<br>..........<br>.......... |
| ៨ | ហានិភ័យគោលដៅដែលបុគ្គលចុះបញ្ជីលក់មូលបត្រអនុវត្តក្នុងការគ្រប់គ្រងហានិភ័យទាក់ទងនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម និងលទ្ធផលជាក់ស្តែងធៀបនឹងហានិភ័យគោលដៅទាំងនេះ<br>..........<br>..........<br>.......... |
| **ផលប៉ះពាល់សង្គម** | |
| ៩ | ចំនួនម៉ោងនៃវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកម្នាក់<br>..........<br>..........<br>.......... |
| ១០ | គ្រោះថ្នាក់ការងារ និងអត្រាមរណភាពពេលបំពេញការងារ<br>..........<br>..........<br>.......... |
| ១១ | គោលនយោបាយ ឬការប្តេជ្ញារបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ទាក់ទងនឹងការគាំពារកុមារ និងការងារដោយបង្ខំ<br>..........<br>..........<br>.......... |
| ១២ | គោលនយោបាយពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹង រួមទាំងបណ្តឹងរបស់បុគ្គលិកចំពោះបុគ្គលចុះបញ្ជីលក់មូលបត្រ<br>..........<br>..........<br>.......... |
| ១៣ | គោលនយោបាយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ<br>..........<br>..........<br>.......... |
| ១៤ | គោលនយោបាយពាក់ព័ន្ធនឹងការរាយការណ៍ពីកំហុសឆ្គងដោយសម្ងាត់ (Whistle Blowing)<br>..........<br>..........<br>.......... |
| ១៥ | សមាមាត្រនៃសមាជិកជាស្ត្រីនៅក្នុងក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ជាស្ត្រី<br>..........<br>..........<br>.......... |

| | |
|---|---|
| ១៦ | ចំនួនបុគ្គលិកសរុបបែងចែកតាមភេទ |
| ១៧ | គោលនយោបាយពាក់ព័ន្ធនឹងការលើកកម្ពស់ពិពិធកម្មយេនឌ័រ |
| ១៨ | ការពិពណ៌នាអំពីគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច |
| **ផលប៉ះពាល់បរិស្ថាន** | |
| ១៩ | ការពិពណ៌នាអំពីផលប៉ះពាល់សំខាន់ៗនៃសកម្មភាពអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រទៅលើបរិស្ថាន |
| ២០ | ការពិពណ៌នាអំពីគោលនយោបាយស្តីពីការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃសកម្មភាពអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រទៅលើបរិស្ថាន |
| ២១ | បរិមាណទឹកសរុបដែលត្រូវបានទាញយកមកប្រើនៅក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ |
| ២២ | សមាមាត្រទឹកកខ្វក់ដែលត្រូវបានបង្កើត សម្អាត និងកែច្នៃឡើងវិញដោយបុគ្គលចុះបញ្ជីលក់មូលបត្រ |
| ២៣ | កាកសំណល់រឹងសរុបដែលកើតចេញពីប្រតិបត្តិការ និងអាជីវកម្ម របស់បុគ្គលចុះបញ្ជីលក់មូលបត្រ |
| ២៤ | សមាមាត្រនៃសំណល់រឹងដែលបានកែច្នៃ ឬស្តារឡើងវិញដោយបុគ្គលចុះបញ្ជីលក់មូលបត្រ |

| ផលប៉ះពាល់អាកាសធាតុ | |
|---|---|
| ២៥ | ផលប៉ះពាល់សំខាន់ៗលើអាកាសធាតុ ដែលបណ្តាលមកពីសកម្មភាពអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ |
| ២៦ | ការពិពណ៌នាអំពីគោលនយោបាយស្តីពីការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃសកម្មភាពអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រទៅលើអាកាសធាតុ |
| ២៧ | បរិមាណថាមពលសរុបដែលត្រូវបានប្រើប្រាស់ក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ |
| ២៨ | សមាមាត្រនៃការប្រើប្រាស់ថាមពលកកើតឡើងវិញ នៅក្នុងប្រតិបត្តិការ និងអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ |
| ២៩ | បរិមាណថាមពលសរុបដែលត្រូវបានផលិត និងសមាមាត្រនៃថាមពលកកើតឡើងវិញ ដែលត្រូវបានផលិតដោយបុគ្គលចុះបញ្ជីលក់មូលបត្រ |
| ៣០ | វិសាលភាព ១÷ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដោយផ្ទាល់ |
| ៣១ | វិសាលភាព ២÷ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដោយប្រយោល |

ចំណុច ៨ ៩ ១០ ១៥ ១៦ ២១ ២២ ២៣ ២៤ ២៧ ២៨ ២៩ ៣០ និង៣១ នៃតារាង "ក" នេះ *បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញព័ត៌មានដែលមានលក្ខណៈដែលអាចប្រៀបធៀបបាន។*

## តារាង "ខ"

| | |
|---|---|
| **អភិបាលកិច្ចប្រកបដោយចីរភាព** | |
| ១ | បុគ្គលចុះបញ្ជីលក់មូលបត្រគួរពិចារណាបញ្ហាពាក់ព័ន្ធនឹងកត្តាអាកាសធាតុ បរិស្ថាន និងសង្គម នៅក្នុងគោលនយោបាយលាភការ និងប្រាក់បំណាច់សម្រាប់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់បុគ្គលចុះបញ្ជីលក់មូលបត្រ<br>..................................................<br>..................................................<br>.................................................. |
| ២ | ដំណើរការក្នុងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងកត្តាបរិស្ថាន និងសង្គមដែលកើតចេញពីផល-បត្រកម្ចី និងប្រតិបត្តិការឥណទានផ្សេងៗ (សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ)<br>..................................................<br>..................................................<br>.................................................. |
| **ផលប៉ះពាល់សង្គម** | |
| ៣ | ដំណើរការដែលប្រើប្រាស់ដោយក្រុមប្រឹក្សាភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្នុងការត្រួតពិនិត្យគោលនយោបាយប្រឆាំងអំពើពុករលួយ<br>..................................................<br>..................................................<br>.................................................. |
| ៤ | វគ្គបណ្តុះបណ្តាលស្តីពី ការប្រឆាំងអំពើពុករលួយដែលផ្តល់ដល់និយោជិតរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្នុងឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន<br>..................................................<br>..................................................<br>.................................................. |
| ៥ | ការសង្ខេបអំពីការមិនអនុលោមទៅតាមគោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយ និងវិធានការរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ (ការបណ្តេញបុគ្គលិក ការពិន័យ សំណង)<br>..................................................<br>..................................................<br>.................................................. |
| ៦ | ក្រមសីលធម៌វិជ្ជាជីវៈរបស់បុគ្គលចុះបញ្ជីលក់មូលបត្រសម្រាប់គ្រប់គ្រងលក្ខខណ្ឌសុវត្ថិភាពការងារ ពលកម្មកុមារ ការងារដោយបង្ខំ រួមទាំងលក្ខខណ្ឌពាក់ព័ន្ធនឹងបញ្ហាទាំងនេះដែលធ្វើឡើងរវាងបុគ្គលចុះបញ្ជីលក់មូលបត្រ និងដៃគូអាជីវកម្ម និងអតិថិជនរបស់ក្រុមហ៊ុន<br>..................................................<br>..................................................<br>.................................................. |

| | |
|---|---|
| ៧ | អនុបាតគម្លាតប្រាក់បៀវត្ស ដោយបែងចែកតាមភេទ<br>……<br>……<br>…… |
| **ផលប៉ះពាល់បរិស្ថាន** | |
| ៨ | កម្រិតការបំភាយឧស្ម័ននៃអុកស៊ីតអាសូត (NOx) និងអុកស៊ីតស្ពាន់ធ័រ (SOx) ដោយប្រតិបត្តិការ និងអាជីវកម្ម របស់បុគ្គលចុះបញ្ជីលក់មូលបត្រ<br>……<br>……<br>…… |
| ៩ | កម្រិតនៃសារធាតុគីមីអាសូត ផូស្វ័រ និងសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុនៅក្នុងទឹកកខ្វក់ដែលបញ្ចេញចោលដោយប្រតិបត្តិការ និងអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ<br>……<br>……<br>…… |
| ១០ | កម្រិតនៃតម្រូវការអុកស៊ីសែននៅក្នុងទឹកកខ្វក់ដែលបញ្ចេញចោលដោយប្រតិបត្តិការ និងអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ<br>……<br>……<br>…… |
| **ផលប៉ះពាល់អាកាសធាតុ** | |
| ១១ | វិសាលភាព ៣÷ ការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ និងអាជីវកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដោយផ្ទាល់ និងប្រយោល<br>……<br>……<br>…… |

---

ចំណុច ៧ ៨ ៩ ១០ និង១១ នៃតារាង "ខ" នេះ *បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញព័ត៌មានដែលមានលក្ខណៈដែលអាចប្រៀបធៀបបាន។*